# សេចក្តីណែនាំស្តីពីដំណោះស្រាយបញ្ហាសម្រាប់ប្រអប់ឧបករណ៍បម្លែងពីឌីជីថល-ទៅ-អាណាឡូក និងទូរទស្សន៍ឌីជីថល

**FCC**

**ឯកសារការពិតរបស់អតិថិជន**

ការផ្លាស់ប្តូរទៅកាន់ទូរទស្សន៍ឌីជីថល (DTV) សំដៅទៅកាន់តម្រូវការដែលទាមទារអោយស្ថានីយ៍ចាក់ផ្សាយទូរទស្សន៍ពេញកម្លាំងថាមពលទាំងអស់ បញ្ឈប់ការចាក់ផ្សាយនៅក្នុងទម្រង់អាណាឡូក ហើយបង្វែរមកចាក់ផ្សាយជាលក្ខណៈឌីជីថលតែប៉ុណ្ណោះបន្ទាប់ពីថ្ងៃទី 17 ខែ កុម្ភៈ ឆ្នាំ 2009 ។ ស្ថានីយ៍ចាក់ផ្សាយទាំងឡាយ នៅក្នុងទីផ្សារសហរដ្ឋអាមេរិកទាំងអស់ បច្ចុប្បន្នកំពុងចាក់ផ្សាយទាំងនៅក្នុងទម្រង់អាណាឡូក ហើយនិងទម្រង់ឌីជីថល ។ ប្រសិនបើជាអ្នកមានការពិបាកមើលស្ថានីយ៍ចាក់ផ្សាយជាទម្រង់ឌីជីថលនៅក្នុងតំបន់របស់អ្នក សេចក្តីណែនាំស្តីពីដំណោះស្រាយបញ្ហានេះ ផ្តល់ជូននូវបញ្ជីការតភ្ជាប់ និងការណែនាំពីការចាប់បាននៃសញ្ញាឌីជីថល ។

## ការត្រួតពិនិត្យការតភ្ជាប់របស់អ្នក

- ចូរពិនិត្យថាប្រអប់ឧបករណ៍សញ្ញាឌីជីថលទៅអាណាឡូក (ឬទូរទស្សន៍ឌីជីថល) របស់អ្នកត្រូវបានភ្ជាប់ត្រឹមត្រូវ ។ ចូរធ្វើអោយប្រាកដថាអង់តែនរបស់អ្នកបានភ្ជាប់ជាមួយរន្ធស៊ុកបញ្ចូលអង់តែននៃប្រអប់ឧបករណ៍បម្លែងពីឌីជីថល-ទៅ-អាណាឡូក (ឬទូរទស្សន៍ឌីជីថល) ។ ប្រសិនបើ ប្រើប្រអប់ឧបករណ៍បម្លែងពីឌីជីថល-ទៅ-អាណាឡូក ក៏ត្រូវធានាអោយបានថារន្ធដោតចេញនៃអង់តែនឧបករណ៍បម្លែងបានភ្ជាប់ជាមួយរន្ធស៊ុកបញ្ចូលអង់តែនរបស់ទូរទស្សន៍អាណាឡូករបស់អ្នក ។ សូមមើលសេចក្តីណែនាំពីការប្រើប្រាស់របស់ម្ចាស់ផលិតឧបករណ៍ទាំងនេះ ប្រសិនបើអ្នកមិនយល់ច្បាស់ពីរបៀបតភ្ជាប់ត្រឹមត្រូវ ។
- ចូរប្រាកដថា ឧបករណ៍ទាំងអស់របស់អ្នកបានដោតបញ្ចូល ហើយភ្លើងរបស់ពួកវាបើក ។
- ប្រសិនបើអ្នកមានប្រអប់ឧបករណ៍បម្លែងពីឌីជីថលទៅអាណាឡូក សូមបើកទូរទស្សន៍ទម្រង់អាណាឡូករបស់អ្នកមើលប៉ុស្តិ៍លេខ 3 ។ អ្នកនឹងឃើញមែនញូតម្លើងមួយ ឬរូបភាពបង្ហាញនៅអេក្រង់ទូរទ្សន៍របស់អ្នក ។ ប្រសិនបើអ្នកមិនឃើញមែនញូ ឬក៏រូបភាពនោះសូមបើកទូរទស្សន៍មើលប៉ុស្តិ៍លេខ 4 ។ ប្រសិនបើនៅតែមើលមិនឃើញមែនញូតម្លើង ឬក៏រូបភាពនោះ សូមពិនិត្យមើលការតភ្ជាប់របស់អ្នកម្តងទៀត ។

## ការធ្វើការស្កេនរកមើលប៉ុស្តិ៍

- ប្រអប់ឧបករណ៍បម្លែងពីឌីជីថលទៅអាណាឡូក (ឬទូរទស្សន៍ឌីជីថល) មានប៊ូតុងមួយ ជាធម្មតានៅលើឧបករណ៍បញ្ជាពីចម្ងាយដែលមានឈ្មោះថា “set-up” ឬ “menu” ឬក៏ពាក្យស្រដៀងនេះ ។ សូមចុចប៊ូតុងនោះដើម្បី ចូលប្រើមែនញូតម្លើង ។ នៅពេលប្រើប្រាស់ប៊ូតុងសញ្ញាព្រួញប្រាប់ពីទិសដៅនៅលើឧបករណ៍បញ្ជាពីចម្ងាយ សូមបង្វិលទៅកាន់មែនញូជម្រើសដែលអាចអោយអ្នកធ្វើការ "ស្កេនរកមើលប៉ុស្តិ៍" បាន ។ ការស្កេនរកមើលប៉ុស្តិ៍ នឹងស្វែងរកប៉ុស្តិ៍ទាំងឡាយណាដែលចាក់ផ្សាយជាទម្រង់ឌីជីថល ដែលមាននៅក្នុងតំបន់របស់អ្នក ។ សូមមើល សេចក្តីណែនាំពីការប្រើប្រាស់របស់ម្ចាស់ផលិតឧបករណ៍បម្លែងឌីជីថល-ទៅ-អាណាឡូក (ឬទូរទស្សន៍ឌីជីថល) សម្រាប់ការណែនាំលំអិតពីរបៀបធ្វើការស្កេនរកមើលប៉ុស្តិ៍ចំពោះឧបករណ៍របស់អ្នកនោះ ។
- នៅពេលស្កេនប៉ុស្តិ៍ចប់ អ្នកនឹងអាចបើកមើលប៉ុស្តិ៍ដែលចាក់ផ្សាយជាទម្រង់ឌីជីថលទាំងឡាយដែលចាប់ដោយអង់តែនរបស់អ្នក ។ **អ្នកគួរធ្វើការស្កេនរកមើលប៉ុស្តិ៍ជាទៀងទាត់ ដើម្បីពិនិត្យមើលថាតើមានប៉ុស្តិ៍ចាក់ផ្សាយជាទម្រង់ឌីជីថលបន្ថែមទៀតទេដែរឬអត់ ។**

## ការកែតម្រូវអង់តែនរបស់អ្នក

- ការកែតម្រូវតិចតួចចំពោះអង់តែនរបស់អ្នក អាចធ្វើអោយមានភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងចំនួននៃប៉ុស្តិ៍ឌីជីថល ដែលអ្នកអាចចាប់បាន ។ ប្រសិនបើអ្នកមានអង់តែននៅក្នុងផ្ទះ សូមព្យាយាមតម្លើងហើយដាក់វាអោយនៅក្បែរជញ្ជាំងផ្ទះខាងក្រៅរបស់អ្នក ។ បន្ទាប់ពីកែតម្រូវអង់តែនរបស់អ្នកហើយ ចូរធ្វើការស្កេនរកមើលប៉ុស្តិ៍ផ្សេងៗទៀត ដើម្បីអោយដឹង ថាតើការចាប់យកប៉ុស្តិ៍របស់អ្នកបានប្រសើរឡើងឬទេ ។
- ខណៈពេលកំពុងកែតម្រូវអង់តែនរបស់អ្នក វាអាចមានប្រយោជន៍ដែលអ្នកមើល "កុងទ័របង្ហាញកម្លាំង" សញ្ញានៅលើប្រអប់ឧបករណ៍បម្លែងពីឌីជីថល-ទៅ-អាណាឡូក (ឬទូរទស្សន៍ឌីជីថល) ដើម្បីកំណត់ថាតើ ការកែតម្រូវរបស់អ្នក កំពុងតែធ្វើអោយកម្លាំងសញ្ញាកើនឡើងឬទេ ។ ជាធម្មតា កុងទ័របង្ហាញកម្លាំងសញ្ញាអាចចូលមើលបានតាមលក្ខណៈពិសេសរបស់មែនញូនៅលើឧបករណ៍បញ្ជាពីចម្ងាយរបស់អ្នក ។ សូមមើល សេចក្តីណែនាំពីការប្រើប្រាស់របស់ម្ចាស់ផលិតឧបករណ៍របស់អ្នកសម្រាប់ការណែនាំលំអិត ពីរបៀបចូលមើលកុងទ័របង្ហាញកម្លាំងសញ្ញា ។ សូមចងចាំថា ធ្វើការស្កេនរកមើលប៉ុស្តិ៍ផ្សេងទៀត បន្ទាប់ពីកែតម្រូវអង់តែនរបស់អ្នកហើយ ។
- ស្ថានីយ៍ទូរទស្សន៍ទាំងឡាយដែលចាក់ផ្សាយនៅក្នុងទម្រង់ឌីជីថលប្រើប្រាស់ទាំងកម្រិតរលក VHF (ប៉ុស្តិ៍លេខ 2-13) ហើយនិងកម្រិតរលកសញ្ញា UHF (ប៉ុស្តិ៍លេខ 14-51) ។ អង់តែនប្រើប្រាស់នៅក្នុងផ្ទះជាច្រើនប្រើប្រាស់ "អង់តែនត្រចៀកទន្សាយ" សម្រាប់ចាប់យករលកសញ្ញា VHF និងអង់តែនម៉ាក “loop” ឬ “bow-tie” សម្រាប់ចាប់យករលកសញ្ញា UHF ។ ចូរប្រាកដថា អ្នកកំពុងប្រើប្រាស់អង់តែនមួយដែលអាចចាប់យកទាំងរលកសញ្ញា VHF ហើយនិង UHF ហើយបានភ្ជាប់វាត្រឹមត្រូវ ។

FCC

Federal Communications Commission ▪ Consumer & Governmental Affairs Bureau ▪ 445 12th St., SW ▪ Washington, DC 20554

1-888-CALL-FCC (1-888-225-5322) ▪ TTY: 1-888-TELL-FCC (1-888-835-5322) ▪ Fax: 1-866-418-0232 ▪ www.fcc.gov/cgb

**<u>ប្រសិនបើអ្នកតែជួបការលំបាក :</u>**

- រហូតដល់ថ្ងៃទី 17 ខែ កុម្ភៈ ឆ្នាំ 2009 ស្ថានីយ៍មួយចំនួន នឹងដំណើរការដោយកម្រិតថាមពលដែលបានកាត់បន្ថយ ។ ប្រសិនបើអ្នកចាប់ស្ថានីយ៍ទូរទស្សន៍ដែលចាក់ផ្សាយជាទម្រង់ឌីជីថលមិនបាន នេះមិនមានន័យថាមានបញ្ហាជាមួយនឹងអង់តែន ឬក៏ប្រអប់ឧបករណ៍បម្លែងពីឌីជីថល-ទៅ-អាណាឡូក (ឬទូរទស្សន៍ឌីជីថល) របស់អ្នកឡើយ ។ ចូរពិនិត្យមើលជាមួយស្ថានីយ៍ទូរទស្សន៍ ដើម្បីដឹងថាតើពួកគេមានគម្រោងធ្វើការផ្លាស់ប្តូរ ដែលធ្វើអោយការចាប់យកប៉ុស្តិ៍បានប្រសើរឡើងដែរឬអត់ ។
- នៅពេលសញ្ញាទូរទស្សន៍អាណាឡូកមួយចុះខ្សោយ ឬ មានការឆ្លង នោះសញ្ញាស្តាទិក ព្រិល ការខូចរូបភាព នឹងលេចឡើងជាញឹកញាប់នៅលើអេក្រង់ ។ ការចាក់ផ្សាយក្នុងទម្រង់ឌីជីថល នឹងផ្តល់រូបភាពច្បាស់ តែទោះជាយ៉ាងណា ប្រសិនបើសញ្ញាធ្លាក់ចុះក្រោមកម្លាំងអប្បបរមាណាមួយនោះ រូបភាពអាចលេចបាត់ទៅវិញ ។ "ឥទ្ធិពលធ្លាក់ចុះ" នេះ មានន័យថា ប្រសិនបើអ្នកមើលស្ថានីយ៍ទូរទស្សន៍ទាំងឡាយណាដែលចាក់ផ្សាយក្នុងទម្រង់អាណាឡូកដែលមានស្តាទិក និងការខូចរូបភាព អ្នកប្រហែលជាអាចកែតម្រូវ ឬបង្កើនសមត្ថភាពប្រព័ន្ធអង់តែនរបស់អ្នក ។
- អង់តែននៅក្នុងផ្ទះធម្មតាផ្តល់នូវសមត្ថភាពប្រតិបត្តិតូចបំផុត ដែលមិនសមស្របចំពោះទីតាំងរបស់អ្នក ។ ប្រសិនបើអ្នកមិនអាចចាប់យកប៉ុស្តិ៍ដែលអ្នកពេញចិត្ត ជាមួយនឹងអង់តែននៅក្នុងផ្ទះបច្ចុប្បន្នរបស់អ្នក អ្នកប្រហែលជាចង់បានអង់តែននៅផ្ទះមួយ ដែលមានលក្ខណៈពិសេសដើម្បីចាប់បានរលកសញ្ញា UHF កាន់តែប្រសើរឡើង ហើយនិង/ឬ ជាឧបករណ៍បង្កើនកំលាំងរលកសញ្ញាដែលទទួលបានមួយ (ជាញឹកញាប់សំដៅទៅអង់តែននៅក្នុងផ្ទះដែលសកម្មមួយ) ។
- ជាទូទៅ អង់តែននៅក្រៅផ្ទះ នឹងចាប់រលកសញ្ញាបានប្រសើរជាងអង់តែននៅក្នុងផ្ទះ ។ តែទោះជាយ៉ាងណា សមត្ថភាពប្រតិបត្តិការនៃអង់តែនក្រៅផ្ទះ អាចថយចុះនៅពេលណាមួយដោយសារតែការប្រឈមនឹងបរិយាកាស ។ ប្រសិនបើអ្នកមានបញ្ហា សូមពិនិត្យរកមើលការតខ្សែអង់តែនដែលរលុង ឬច្រែះកាត់ គ្រឿងអង់តែនបាក់បែក ហើយពិនិត្យមើលថាអង់តែនបានដាក់តាមទិសដៅត្រឹមត្រូវដែរឬអត់ ។
- ព្យាយាមរក្សាប្រវែងរបស់ខ្សែអង់តែនរវាងអង់តែន និងឧបករណ៍បម្លែងពីឌីជីថល-ទៅ-អាណាឡូក (ឬទូរទស្សន៍ឌីជីថល) អោយបានខ្លីតាមតែអាចទៅរួច ដើម្បីចាប់យករលកសញ្ញាល្អបំផុត ។
- "ឧបករណ៍បំបែក" ដែលត្រូវបានប្រើដើម្បីភ្ជាប់អង់តែនទោលមួយទៅកាន់ប្រអប់ឧបករណ៍បម្លែងពីឌីជីថល-ទៅ-អាណាឡូកច្រើន (ឬទូរទស្សន៍ឌីជីថល) កាត់បន្ថយបរិមាណរលកសញ្ញាចំពោះឧបករណ៍នីមួយៗ ។ ប្រសិនបើអ្នកមានបញ្ហា សូមពិនិត្យមើលថាតើការចាប់យករលកសញ្ញាបានប្រសើរឡើងទេ ដោយមិនប្រើឧបករណ៍បំបែក ។ ក្នុងករណីមួយចំនួន ឧបករណ៍បំបែក "សកម្ម" មួយដែលមានឧបករណ៍បង្កើនកម្លាំងរលកសញ្ញា អាចជួយដោះស្រាយបញ្ហាបាន ។
- ប្រសិនបើអ្នកនៅក្បែរកន្លែងចាក់ផ្សាយរបស់ស្ថានីយ៍ ការចាប់យកប៉ុស្តិ៍ស្ថានីយ៍នោះ ក៏ដូចជាស្ថានីយ៍ផ្សេងៗទៀត អាចបង្អាក់ដោយសារតែ " ភាពលើសលុប" នៃរលកសញ្ញា ។ ចូរពិចារណាពីការប្រើប្រាស់ឧបករណ៍បន្ថយកម្លាំងរលកសញ្ញា ឬយកឧបករណ៍បង្កើនកម្លាំងរលកសញ្ញាចេញ ដើម្បីធ្វើអោយការចាប់យកប៉ុស្តិ៍របស់អ្នកប្រសើរឡើង ។
- ប្រសិនបើអ្នកសម្រេចចិត្តប្តូរ ឬបង្កើនសមត្ថភាពអង់តែននៅក្នុង ឬក្រៅផ្ទះរបស់អ្នក មានប្រភេទអង់តែនជាច្រើនលក់រាយនៅតាមហាងអេឡិចត្រូនិចក្នុងតម្លៃខុសៗគ្នា។ គេហទំព័រដូចជា <u>www.antennaweb.org</u> ផ្តល់នូវព័ត៌មានស្តីពីទីតាំងនៃកន្លែងចាក់ផ្សាយទាំងឡាយ ហើយនិងប្រភេទអង់តែននៅក្រៅផ្ទះ ដែលសមស្របចំពោះស្ថានីយ៍ដែលអ្នកចង់ចាប់យកប៉ុស្តិ៍មកទស្សនា ។ ប្រសិនបើជាអ្នកត្រូវការជំនួយក្នុងការបង្កើនសមត្ថភាពប្រព័ន្ធអង់តែនរបស់អ្នក សូមពិនិត្យរកមើលអ្នកលក់អង់តែន ឬអ្នកតម្លើងអង់តែននៅតាមតំបន់របស់អ្នក ។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការផ្លាស់ប្តូរ DTV សូមចូលមើលគេហទំព័រ <u>www.dtv.gov</u> ឬទំនាក់ទំនង FCC តាមអ៊ីម៉ែល <u>dtvinfo@fcc.gov</u> ឬក៏ទូរស័ព្ទមកកាន់ 1-888-CALL-FCC (1-888-225-5322) ជាសម្លេង ឬ 1-888-TELL-FCC (1-888-835-5322) TTY ផ្ញើទូរសារមកកាន់ 1-866-418-0232 ឬ សរសេរសំបុត្រមក :

Federal Communications Commission<br>
Consumer & Governmental Affairs Bureau<br>
Consumer Inquiries and Complaints Division<br>
445 12th Street, SW<br>
Washington, DC 20554

*###*

*សម្រាប់អត្ថបទនេះ ឬក៏ការបោះពុម្ពណាមួយចែកជូនអតិថិជនក្នុងទម្រង់ដែលអាចទទួលបាន (ជាអត្ថបទអេឡិចត្រូនិច ASCII ជាអក្សរសម្រាប់មនុស្សងងឹតភ្នែក ការបោះពុម្ពធំៗ ឬក៏ជាសម្លេង ) សូមសរសេរ ឬក៏ទូរស័ព្ទមកកាន់យើងខ្ញុំតាមរយៈអាសយដ្ឋាន ឬលេខទូរស័ព្ទខាងក្រោម ឬក៏ផ្ញើអ៊ីម៉ែលទៅកាន់ **<u>FCC504@fcc.gov</u>** ។*

*ឯកសារនេះសម្រាប់គោលបំណងអប់រំអ្នកប្រើប្រាស់តែប៉ុណ្ណោះ ហើយមិនមានបំណងណាមួយធ្វើឱ្យមានការប៉ះពាល់ដល់ដំណើរការបណ្តឹង ឬករណីណាមួយដែលជាប់ពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃបញ្ហា ឬបញ្ហាផ្សេងៗទៀតនោះទេ ។*

9/23/08